**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ: ០១៩៦ សជណ.អក.មអជ

ថ្ងៃសុក្រ ០៦កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសជម្រាបជូនសេវាករអគ្គិសនីផ្តល់សេវាកម្មអគ្គិសនីនៅតំបន់ជនបទឲ្យបានជ្រាបថាៈ ក្រោមការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅជនបទ **រាជរដ្ឋាភិបាលកម្ពុជា** មាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ ២០១៥-២០២០"។ អនុវត្តន៍តាមផែនការយុទ្ធសាស្ត្រនេះ នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (បន្ទាប់ពីនេះទៅហៅថា "ម.អ.ជ.") ទទួលបន្ទុកបន្ថយអត្រាថ្លៃលក់អគ្គិសនីបន្ថែមជូនគ្រួសារជនបទក្រីក្រ ដែលប្រើប្រាស់អគ្គិសនីតាមផ្ទះ និងជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់ការបូមទឹកធ្វើកសិកម្មនៅតំបន់ជនបទពីម៉ោង ៩យប់ ដល់ម៉ោង ៧ព្រឹក។

ដើម្បីឲ្យការអនុវត្តផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីដែលបានដាក់ចេញដោយប្រមុខ **រាជរដ្ឋាភិបាលកម្ពុជា** និងក្នុងគោលបំណងឲ្យការអនុវត្តប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងសមធម៌ **អគ្គិសនីកម្ពុជា** ស្នើសេវាករអគ្គិសនីកំពុងផ្តល់សេវាកម្មអគ្គិសនីនៅតំបន់ជនបទមេត្តាសហការដោយឈរលើស្មារតីទទួលខុសត្រូវខ្ពស់ និងផ្តល់ទិន្នន័យពីបរិមាណអគ្គិសនីដែលគ្រួសារជនបទបានប្រើប្រាស់តាមផ្ទះ និងបរិមាណអគ្គិសនីដែលបានប្រើប្រាស់សម្រាប់ការបូមទឹកធ្វើកសិកម្មនៅតំបន់ជនបទឲ្យបានសុក្រឹត និងត្រឹមត្រូវ រួមទាំង ឯកសារពាក់ព័ន្ធជូនមក ម.អ.ជ. ដើម្បីពិនិត្យ និងទូទាត់ថ្លៃប្រើប្រាស់អគ្គិសនីបំពេញបន្ថែមជូនសេវាករអគ្គិសនីជំនួសគ្រួសារជនបទដែលបានប្រើប្រាស់អគ្គិសនីតាមផ្ទះ និងសម្រាប់ការបូមទឹកធ្វើកសិកម្មនៅតំបន់ជនបទទាន់ពេលវេលា។

ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនេះ ជាកម្មវិធីអនុវត្តន៍បន្តពីឆ្នាំ២០១៦ និងនៅបន្តអនុវត្តន៍ក្នុងឆ្នាំ២០១៩។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

**ចម្លងជូនៈ**

- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ